# អនុស្សរណៈយោគយល់គ្នា

# ស្តីពី

# កិច្ចសហប្រតិបត្តិការទ្វេភាគីស្តីពីកម្មសិទ្ធិបញ្ញា

# រវាង

# ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
# នៃព្រះរាជាណាចក្រកម្ពុជា

# និង

# អគ្គភាពកម្មសិទ្ធិបញ្ញារដ្ឋ
# នៃសាធារណរដ្ឋប្រជាមានិតចិន

អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន(ដែលហៅកាត់ថា“the SIPO”)និងក្រសួងឧស្សាហកម្ម និងសិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជា(ដែលហៅកាត់ថា “the MIH”) ភាគីនីមួយៗចាប់ពីពេលនេះទៅហៅថា “ភាគី” ហើយភាគីទាំងពីរហៅថា “គូភាគី”។

- **ពិចារណាលើតម្លៃ** និងសារសំខាន់នៃកម្មសិទ្ធិបញ្ញាសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្លាស់ប្តូរបច្ចេកវិជ្ជា
- **ទទួលស្គាល់**សេចក្តីត្រូវការដើម្បីជំរុញធ្វើឲ្យប្រសើរឡើង និងពង្រឹងប្រព័ន្ធកម្មសិទ្ធិបញ្ញាក្នុងទិដ្ឋភាពផ្តល់នូវការឆ្លើយតបដ៏មានប្រសិទ្ធភាពទៅនឹងភាពប្រឈមទាំងឡាយ ដែលកើតឡើងពីការប្រើប្រាស់បច្ចេកវិជ្ជាថ្មី
- **យល់ឃើញ** សម្រាប់អភិវឌ្ឍបន្ថែមទៀតនូវសហប្រតិបត្តិការរវាងអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីដោះស្រាយបញ្ហាប្រឈមនៃសតវត្សនេះ និងជំរុញការផ្លាស់ប្តូរសេដ្ឋកិច្ច រវាងកម្ពុជា និងចិន និង
- **ពិនិត្យ**ទៅលើទំហំអភិវឌ្ឍនៃកម្មសិទ្ធិបញ្ញា
- បានព្រមព្រៀងគ្នាដូចខាងក្រោម៖

## ប្រការ១

## កម្មវត្ថុ

គោលបំណងនៃអនុស្សរណៈយោគយល់គ្នា (ដែលហៅកាត់ថា“MOU”) គឺបង្កើតយន្តការទូលំទូលាយ និងភាពបត់បែនសម្រាប់ជាមគ្គុទ្ទេស និងពន្លឿនសកម្មភាពកិច្ចសហប្រតិបត្តិការ រវាងភាគីទាំងពីរ ក្នុងវិស័យកម្មសិទ្ធិឧស្សាហកម្ម ស្របតាមការទទួលខុសត្រូវរបស់ភាគីទាំងពីរនៅក្នុងវិស័យនេះ។

តាមរយៈអនុស្សរណៈនេះ ភាគីទាំងពីរបានយល់ព្រមធ្វើកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍ និងពង្រីកប្រព័ន្ធប្រកាសនីយបត្រតក្កកម្ម និងគំនូរឧស្សាហកម្ម នៅក្នុងប្រទេសចិន និងប្រទេសកម្ពុជា។

## ប្រការ២

## សាវតា

អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន គឺជាស្ថាប័នរដ្ឋមួយដែលរាយការណ៍ផ្ទាល់ទៅក្រុមប្រឹក្សារដ្ឋ ដែលទទួលខុសត្រូវចម្បងគ្របដណ្តប់លើ ការដាក់ពាក្យសុំ ការត្រួតពិនិត្យ ការត្រួតពិនិត្យឡើងវិញ ការចុះបញ្ជីផ្តល់ប្រកាសនីយបត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម និងសៀគ្វីបង្រួម ការរៀបចំ និងការសម្របសម្រួលការងារការពារកម្មសិទ្ធិបញ្ញាទូទាំងប្រទេស រួមទាំងការដឹកនាំ ការអភិវឌ្ឍ និងការអនុវត្តយុទ្ធសាស្ត្រកម្មសិទ្ធិបញ្ញាជាតិ និងគម្រោងកម្មសិទ្ធិបញ្ញារយៈពេលប្រាំឆ្នាំ ដូចជាការបង្កើតច្បាប់ និងគោលនយោបាយណ៍ទាក់ទងនឹងកម្មសិទ្ធិបញ្ញា ការសម្របសម្រួលជាទូទៅនូវកម្មសិទ្ធិបញ្ញាទាក់ទងនឹងបរទេសពិសេស ការងារទាក់ទងនឹងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម គឺជាក្រសួងដែលបានបង្កើតដោយព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៣។ អនុក្រឹត្យលេខ ៥៧៥.អនក្រ.បក ចុះថ្ងៃទី២៤ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានកំណត់ឲ្យ

ក្រសួងនេះទទួលបន្ទុកក្នុងការគ្រប់គ្រងអភិវឌ្ឍ និងការជំរុញឧស្សាហកម្ម និងសិប្បកម្មសហគ្រាសធុនតូច និងមធ្យម កម្មសិទ្ធិឧស្សាហកម្ម និងការច្នៃប្រឌិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ៣
## វិស័យកិច្ចសហប្រតិបត្តិការ

១. គូភាគីនឹងធ្វើកិច្ចសហប្រតិបត្តិការតាមវិស័យដូចខាងក្រោម៖

១) កិច្ចសហប្រតិបត្តិការបច្ចេកទេស

ក. វិទ្យាស្ថានក្រោមឱវាទនៃអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិននឹងផ្ដល់ជូននូវសេវាកម្មស្រាវជ្រាវ និងវាយតម្លៃ ហើយដើរតួនាទីជាអាជ្ញាធរស្រាវជ្រាវនិងត្រួតពិនិត្យសម្រាប់ការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្រសួងឧស្សាហកម្ម និងសិប្បកម្មទទួលស្គាល់ ប្រកាសនីយបត្រតក្កកម្មដែលបានផ្ដល់នៅអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន។

ខ. អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងសហការចែករំលែកក្នុងការងារត្រួតពិនិត្យប្រកាសនីយបត្រតក្កកម្ម ។

២) ការអភិវឌ្ឍធនធានមនុស្ស

ក. អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវសហការគ្នាក្នុងការអភិវឌ្ឍធនធានមនុស្សនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលទាក់ទងនឹងប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាហកម្ម ជាពិសេសសហការជាមួយនឹងនាយកដ្ឋានកម្មសិទ្ធិឧស្សាហម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម។

ខ. កិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍធនធានមនុស្ស នឹងត្រូវបានឧបត្ថម្ភគាំទ្រដោយមធ្យោបាយអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន ដែលមានការបញ្ជូនអ្នកឯកទេសមកជួយកម្ពុជា បញ្ជូនមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្មទៅធ្វើទស្សនកិច្ចសិក្សានៅអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន និង ការិយាល័យប្រកាសនីយបត្រតក្កកម្ម និងគំនូរឧស្សាហកម្មផ្សេងទៀត នៅក្នុងប្រទេសចិន ព្រមទាំងការចូលរួមរបស់មន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងសិក្ខាសាលាដែលរៀបចំ
ដោយ SIPO។

គ. អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងបន្តជួយបណ្ដុះបណ្ដាលឲ្យកាន់តែរឹងមាំដល់មន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងផ្នែកដែលពាក់ព័ន្ធកម្មសិទ្ធិបញ្ញាផ្សេងទៀតដូចជាសហគ្រាសធុនតូច និងមធ្យម (SMEs), សកលវិទ្យាល័យ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ ដែលត្រូវការប្រើប្រាស់ព័ត៌មានដែលទាក់ទងនឹងប្រកាសនីយបត្រតក្កកម្ម និងអ្នកឯកទេសកម្មសិទ្ធិបញ្ញាផ្សេងទៀត។

៣) ការផ្លាស់ប្ដូរបទពិសោធន៍

ក. ផ្លាស់ប្ដូរការអនុវត្តល្អបំផុត បទពិសោធន៍ និងចំណេះដឹង អំពីការគ្រប់គ្រង និងការការពារកម្មសិទ្ធិបញ្ញា ជាពិសេសចំពោះប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាហកម្ម និងគំនូស

បង្ហាញនៃសៀគ្វីបង្រួម

ខ. ផ្លាស់ប្តូរការអនុវត្តល្អបំផុត បទពិសោធន៍ និងចំណេះដឹង អំពីតួនាទីរបស់ភាគីនីមួយៗក្នុងការពន្លឿន និងជំរុញការច្នៃប្រឌិត និងការបង្កើតថ្មីក្នុងវិស័យកម្មសិទ្ធិបញ្ញា

គ. ផ្លាស់ប្តូរការអនុវត្តល្អបំផុត បទពិសោធន៍ និងចំណេះដឹងអំពីតួនាទីរបស់ភាគីនីមួយៗក្នុងការលើកទឹកចិត្តឧស្សាហកម្មឲ្យប្រើប្រាស់កម្មសិទ្ធិបញ្ញាដើម្បីសម្រួលការអភិវឌ្ឍសេដ្ឋកិច្ច និង

ឃ. សហការបណ្តុះបណ្តាលអំពីកម្មសិទ្ធិបញ្ញាដល់អ្នកពាក់ព័ន្ធនឹងផ្នែកកម្មសិទ្ធិបញ្ញា និងសហគមន៍ពាណិជ្ជកម្មក្នុងស្រុក។

២. សកម្មភាពសហប្រតិបត្តិការក្រោមអនុស្សរណៈយោគយល់គ្នានេះ នឹងត្រូវអនុវត្តតាមរយៈការផ្លាស់ប្តូរទៅវិញទៅមកនៃបេសកកម្មជាន់ខ្ពស់ បេសកកម្មបច្ចេកទេស កម្មវិធីការងារ និងមធ្យោបាយផ្សេងទៀតដែលយល់ព្រមដោយគូភាគី។

៣. គូភាគីយល់ព្រម៖

១) សហការរៀបចំខ្លឹមសារ ប្រធានបទ កាលបរិច្ឆេទ និងកិច្ចការលម្អិតផ្សេងទៀតនៃបេសកម្មបច្ចេកទេស កម្មវិធីការងារនិងសកម្មភាពសហប្រតិបត្តិការផ្សេងទៀតដែលស្ថិតនៅក្រោមអនុស្សរណៈយោគយល់គ្នានេះ តាមរយៈផែនការការងារដែលនឹងត្រូវយល់ព្រមដោយភាគីទាំងពីរ។

២) ពិនិត្យលទ្ធភាពពង្រីងកិច្ចសហប្រតិបត្តិការនេះទៅដល់ប្រភេទផ្សេងទៀតនៃកម្មសិទ្ធិបញ្ញា

៣) ពិចារណាទទួលស្គាល់អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋចិន ជាអាជ្ញាធរស្រាវជ្រាវ និងពិនិត្យអន្តរជាតិសម្រាប់តក្កកម្មសម្រាប់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

៤) គ្រប់សកម្មភាពសហប្រតិបត្តិការក្រោមអនុស្សរណៈយោគយល់គ្នានេះ នឹងអាចអនុវត្តបានអាស្រ័យ លើលទ្ធភាពនៃធនធានរបស់ភាគីនីមួយៗ។

## ប្រការ៤
## ផ្នែកហិរញ្ញវត្ថុ

ក្នុងការអនុវត្តសកម្មភាពសហប្រតិបត្តិការក្រោមអនុស្សរណៈយោគយល់គ្នានេះ គឺអាស្រ័យលើលទ្ធភាពហិរញ្ញវត្ថុ និងថវិការបស់ភាគីនីមួយៗ និងការព្រមព្រៀងដោយគូភាគី ដោយអនុលោមទៅតាមថវិកាប្រចាំឆ្នាំ ក្នុងការងារអភិវឌ្ឍរាល់សកម្មភាពកិច្ចសហប្រតិបត្តិការក៏ដូចជាលទ្ធភាពនៃមធ្យោបាយ និងធនធានចាំបាច់ផ្សេងទៀត។

## ប្រការ៥
## មន្ត្រីដែលត្រូវចាត់តាំង

ចំពោះមន្ត្រីដែលត្រូវចាត់តាំងដោយភាគី សម្រាប់អនុវត្តសកម្មភាពសហប្រតិបត្តិការ ក្រោមអនុស្សរណៈយោគយល់គ្នានេះនឹងស្ថិតនៅក្រោមការដឹកនាំ និងការអនុញ្ញាតរបស់ភាគីនោះ ដោយគ្មានការជ្រើសរើសនិយោជិតថ្មីដែលត្រូវបង្កើតឡើងរវាងមន្ត្រីនោះ និងភាគីផ្សេងទៀតឡើយ។ គ្មានភាគីណានឹងត្រូវបានចាត់ទុកជានិយោជកជំនួសមន្ត្រីណាមួយនៃភាគីផ្សេងទៀតឡើយ។

## ប្រការ៦
## អ្នកសម្របសម្រួលសកម្មភាព

គូភាគីនឹងចាត់តាំងអ្នកសម្របសម្រួលរៀងៗខ្លួន ដើម្បីទទួលបន្ទុកការអនុវត្តន៍ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពកិច្ចសហប្រតិបត្តិការ ក្រោមអនុស្សរណៈយោគយល់គ្នានេះ។ អ្នកសម្របសម្រួលខាងលើនេះ នឹងធ្វើការទំនាក់ទំនងបឋមសម្រាប់គ្រប់ការទំនាក់ទំនង រវាងគូភាគីហើយនឹងសម្របសម្រួលសកម្មភាពសហប្រតិបត្តិការទាំងអស់ ក្រោមអនុស្សរណៈយោគយល់គ្នានេះ។

គូភាគីនឹងរៀបចំឲ្យមានឱកាសសម្រាប់មន្ត្រីជួបប្រជុំ និងពិភាក្សាអំពីប្រធានបទសំខាន់ៗ តាមពេលវេលាសមស្រប។ការរៀបចំនេះរាប់បញ្ចូលទាំងការអញ្ជើញបុគ្គលិករបស់ភាគីមួយពីសំណាក់បុគ្គលិកនៃភាគីមួយទៀត ដើម្បីទៅធ្វើទស្សនកិច្ចនៅការិយាល័យរបស់ខ្លួន។

## ប្រការ៧
## វិសោធនកម្ម

អនុស្សរណៈយោគយល់គ្នានេះអាចធ្វើវិសោធនកម្មបានដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីគូភាគី។

## ប្រការ៨
## លក្ខណៈច្បាប់

អនុស្សរណៈយោគយល់គ្នានេះ និងសកម្មភាពសហប្រតិបត្តិការ ក្រោមអនុស្សរណៈយោគយល់គ្នានេះគឺអាស្រ័យទៅលើច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាននៃភាគីនីមួយៗ។ អនុស្សរណៈយោគយល់គ្នានេះមិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗ ក្រោមកិច្ចព្រមព្រៀងអន្តរជាតិណាមួយផ្សេងទៀត ដែលភាគីនោះត្រូវបានជាប់កិច្ចសន្យានោះទេ។

## ប្រការ៩
## ពេលវេលានៃការពិនិត្យឡើងវិញ

គូភាគីនឹងកំណត់ពេលវេលានៃការពិនិត្យឡើងវិញដើម្បី វាយតម្លៃទៅលើកិច្ចសហប្រតិបត្តិការក្រោមអនុស្សរណៈយោគយល់គ្នានេះ មុនដំណាច់ឆ្នាំទីមួយនៃអនុស្សារណៈនេះចូលជាធរមាន។

## ប្រការ១០
## រយៈពេលនិងការបញ្ចប់

អនុស្សរណៈយោគយល់គ្នានេះ នឹងចូលជាធរមាន ចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខានេះដោយគូភាគី ហើយនឹងត្រូវបញ្ចប់រយៈពេលប្រាំ (៥) ឆ្នាំ។

ភាគីនីមួយៗអាចបញ្ឈប់អនុស្សរណៈយោគយល់គ្នានេះ ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីមួយទៀត យ៉ាងតិចមុនរយៈពេលសាបសិប (៣០)ថ្ងៃ។

នៅពេលផុតកំណត់ ឬបញ្ឈប់អនុស្សរណៈយោគយល់គ្នានេះ គូភាគីនឹងពិគ្រោះយោបល់គ្នាទៅវិញទៅមក ហើយបញ្ជាក់ជាលាយលក្ខណ៍អក្សរ ថាតើមានបំណងបន្តសកម្មភាពកិច្ចសហប្រតិបត្តិការដែលកំពុងដំណើរការ ខណៈពេលផុតកំណត់នៃកាលបរិច្ឆេទ ឬបញ្ឈប់អនុស្សរណៈយោគយល់គ្នានេះ។

## ប្រការ១១

## ការពិគ្រោះយោបល់

គូភាគីនឹងពិគ្រោះយោបល់គ្នាតាមការសមស្របអំពីរឿងហេតុដែលអាចកើតឡើង ក្នុងអំឡុងពេលអនុវត្តអនុស្សរណៈយោគយល់គ្នានេះ។

ធ្វើនៅទីក្រុងប៉េកាំង ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៧ ធ្វើឡើងចំនួនពីរច្បាប់ ជាបីភាសា ភាសាចិន ភាសាខ្មែរ និងភាសាអង់គ្លេស អត្ថបទទាំងអស់មានតម្លៃស្មើគ្នា។

**អង្គភាពកម្មសិទ្ធិបញ្ញារដ្ឋ**
**នៃសាធារណរដ្ឋប្រជាមានិតចិន**

**បណ្ឌិត សេន ចាងយូ**
**ប្រធានអង្គភាពកម្មសិទ្ធិបញ្ញារដ្ឋ**
**នៃសារធារណរដ្ឋប្រមានិតចិន**

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**នៃព្រះរាជាណាចក្រកម្ពុជា**

**ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ**
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**